អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦

# សេចក្តីប្រកាសព័ត៌មាន

## សហភាពអឺរ៉ុបទម្លាក់កញ្ចប់ថវិកាឧបត្ថម្ភសម្រាប់ឆ្នាំ ២០១៦ ដល់ អ.វ.ត.ក

អនុវត្តតាមការសន្យាកាលពីឆ្នាំមុនក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុក្នុងទឹកប្រាក់សរុបចំនួន ៨,៩ លានអឺរ៉ូ ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ឆ្នាំ ២០១៥ ដល់ ឆ្នាំ ២០១៦ សហភាពអឺរ៉ុប បានធ្វើការទម្លាក់កញ្ចប់ថវិកាឧបត្ថម្ភចុងក្រោយរបស់ខ្លួនដែលមានទឹកប្រាក់ចំនួន ២,៩ លានអឺរ៉ូ ក្នុងនោះ ថវិកាចំនួន ១,៥ លានអឺរ៉ូ សម្រាប់គាំទ្រភាគីអន្តរជាតិ និង ១,៤ លានអឺរ៉ូទៀតសម្រាប់ភាគីជាតិនៃ អ.វ.ត.ក។

សហភាពអឺរ៉ុបជាម្ចាស់ជំនួយធំមួយក្នុងចំណោមម្ចាស់ជំនួយធំៗបំផុតរបស់ អ.វ.ត.ក ហើយការទម្លាក់កញ្ចប់ថវិកាចុងក្រោយនេះ ធ្វើឲ្យជំនួយហិរញ្ញវត្ថុដែលសហភាពអឺរ៉ុបបានផ្តល់ដល់ អ.វ.ត.ក មានចំនួនសរុប ១៦,២ លានអឺរ៉ូហើយ ចាប់ពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ តាំងពីឆ្នាំ ២០០៦ មក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖ “ក្នុងនាម អ.វ.ត.ក យើងខ្ញុំសូមសម្តែងនូវការដឹងគុណចំពោះការបន្តឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លារបស់សហភាពអឺរ៉ុប”។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត៖ +៨៥៥ (០) ១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ៖ +៨៥៥ (០) ២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត៖ +៨៥៥ (០) ១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុ៖ +៨៥៥ (០) ២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org